# ប្រព័ន្ធកសិកម្មចម្រុះ រវាងការចិញ្ចឹមគោ ការធ្វើស្រែ សណ្តែកបាយ ត្រសក់ និងត្រកួន

## ១. និយមន័យ

ប្រព័ន្ធកសិកម្មចម្រុះ **រវាងការចិញ្ចឹមគោ ការធ្វើស្រែ សណ្តែកបាយ ត្រសក់ និងត្រកួន** គឺជាការធ្វើកសិកម្មដែលមានអន្តរអំពើឲ្យគ្នាទៅវិញទៅមក និងជាពិសេសបានផលចំណេញដល់កសិករយ៉ាងខ្លាំង។ ពិព្រោះថាការចិញ្ចឹមគោ អាចយកលាមកមកធ្វើជាជីដាក់ស្រែ ដាក់ត្រកួន និងដំណាំផ្សេងទៀត។ ការដាំសណ្តែកបាយ វាបានបង្កើនគុណភាពដី ជីជាតិដី និងស្មៅសម្រាប់ទុកឲ្យគោស៊ីផងដែរ។ ការធ្វើស្រែ វាបានផលសម្រាប់ផលិតជាអង្ករ កន្ទក់ ក៏ដូចជាចំបើងទុកឲ្យគោស៊ី ជាពិសេសជញ្ជ្រាំងទុកសម្រាប់គ្របដី គ្របរងដំណាំ ដូចជា ត្រកួន ត្រសក់ ជាដើម ហើយជាពិសេស ការមានប្រព័ន្ធកសិមកម្មបែបនេះក្នុងគ្រួសារ វាបានបង្កភាពងាយស្រួស និងកំណើនសេដ្ឋកិច្ចដល់គ្រួសារ។




## ២. ការរៀបចំប្លង់

តាមរយៈការសិក្សា និងការចុះសង្កេតជាមួយកសិករឃើញថា ការអនុវត្តន៍ប្រព័ន្ធកសិកម្មចម្រុះ បែបនេះមាប្រមាណ ១០ ភាគរយដែលអនុវត្តន៍ប្រព័ន្ធកសិកម្មបែបនេះ។

ជាទូទៅនៅក្នុងភូមិមាន ១០៦ គ្រួសារ ហើយមានគ្រួសារប្រមាណ ១០ គ្រួសារដែលបានអនុវត្តន៍ប្រព័ន្ធកសិកម្មបែបនេះ។ ធាតុសំខាន់នៃប្រព័ន្ធនេះរួមមាន ការចិញ្ចឹមសត្វ ការធ្វើស្រែ និងការដាំបន្លែ និងជាពិសេសប្រព័ន្ធទឹក។

- ទំហំដីលំនៅដ្ឋានមានចាប់ពី ៣០០ ម៉ែត្រការ៉េឡើងទៅ រហូតដល់ដល់ ២ ហិចតាដែលបាន អនុវត្តន៍ប្រព័ន្ធកសិកម្មបែបនេះ។ ពួកគាត់បានអនុត្តន៍ប្រព័ន្ធកសិកម្មបែបនេះ ដើម្បីផ្គត់ផ្គង់ដល់ជីវភាពក្នុងគ្រួសារ និងលក់ទៅទីផ្សារខាងក្រៅ
- គោ គេចាប់ចិញ្ចឹមចាប់ពី ២ក្បាល រហូតដល់ ១៥ ក្បាល ដោយចិញ្ចឹមគោមានទីផ្សារល្អ នៅតំបន់នេះមាន តម្លៃខ្ពស់គួរសម អាចលក់ និងជួយផ្គត់ផ្គង់ដល់ជីវភាពក្នុងគ្រួសារ ហើយជាពិសេសលាមកវាអាចធ្វើជាជីដាក់ដំណាំផ្សេងៗ និងកាត់បន្ថយការទិញជីគីមីផងដែរ



- ត្រសក់ មានកសិករនិយមដាំច្រើនជាងគេ ដែលមានផ្ទៃដាំចាប់ពី ២០០ ម៉ែត្រការ៉េ រហូតដល់ ៥០០ ម៉ែត្រការ៉េ។ វាជាប្រដំណាំដែលមានអាយុខ្លី ទិន្នផលច្រើន ដាំបានទាំងខែប្រាំង និងវស្សាហ៍ ដែលមានតម្លៃទីផ្សារខ្ពស់ និងងាយស្រួលលក់ ដែលអាចឲ្យប្រជាកសិករមួយចំនួនអាចរកប្រាក់ចំនូលបានច្រើនពីវា ក្នុងមួយថ្ងៃចន្លោះពី ៥០ គីឡូ ទៅ ១០០ គីឡូក្រាមក្នុមួយថ្ងៃប៉ុន្តែចាំបាច់កសិករត្រូវចេះបច្ចេកទេស និងមានប្រព័ន្ធទឹកស្រោចស្រប់គ្រប់គ្រាន់



- ត្រកួន មានទំហំចាប់ពី ៥០ ម៉ែត្រការ៉េ រហូតដល់ ២០០ ម៉ែត្រការ៉េ វាជា ប្រភេទ ដំណាំដែលធន់នឹងអាកាសធាតុ អាចដាំបានគ្រប់រដូវ ប៉ុន្តែត្រូវការទឹកច្រើននៅ រដូវប្រាំង។